

# ស្ថានទូតធ្វើកម្មវិធីបង្ហាញការរៀបចំផ្កាបែបបុរាណជប៉ុន

Thu, 12 June 2014 ឈឹម ស្រីនាង

**ភ្នំពេញៈ**ស្ថានទូតជប៉ុនបានរៀបចំកម្មវិធីបង្រៀន និងពន្យល់អំពីសិល្បៈប្រពៃណីដ៏រុងរឿងបំផុតរបស់ប្រទេសជប៉ុនគឺការរៀបចំផ្កាបែបបុរាណរបស់ជប៉ុនហៅថា អ៊ីកេបាណា (Ikebana) ដោយមានការចូលរួមពីសំណាក់ស្ត្រីអ្នកដឹកនាំជាតិ និងអន្តរជាតិចូលរួមស្តាប់និងប្រតិបត្តិផ្ទាល់បន្ទាប់ពីបង្រៀនចប់។

លោក គូម៉ាម៉ារូ យូជី (Kumamaru Yuji ) អគ្គរដ្ឋទូតជប៉ុនប្រចាំប្រទេសកម្ពុជាបានមានប្រសាសន៍ថា អ៊ីកេបាណាគឺប្រពៃណីរៀបចំផ្ការបស់ជប៉ុនដែលបានជឿជាក់ថាផ្តើមឡើងពីការប្រតិបត្តិព្រះពុទ្ធសាសនាជាង១០០០ឆ្នាំមុន។បន្ទាប់មកវាក្លាយទៅជាការប្រតិបត្តិមួយក្នុងសង្គមខាងលើជាមួយនឹងការផ្លាស់ប្តូរពេលវេលាវាមានភាពប្រជាប្រិយឡើងហើយ និងប្រតិបត្តិយ៉ាងទូលំទូលាយក្នុងចំណោមប្រជាជនរស់នៅប្រចាំថ្ងៃដែលទាក់ទងនឹងសិល្បៈ។

សព្វថ្ងៃមិនមែនតែនៅក្នុងប្រទេសជប៉ុននោះទេដែលល្បីខាងសិល្បៈរៀបផ្កាអ៊ីកេបាណា។ ប្រជាប្រិយភាពនៃសិល្បៈបុរាណនេះបានសាយភាយពាសពេញពិភពលោក។



ភ្ញៀវមកពីស្ថានទូតនានាមកចូលរួមក្រេបចំណេះដឹងអំពីសិល្បៈរៀបផ្កាអ៊ីកេបាណា។ ឈឹម ស្រីនាង

លោកបានថ្លែងថា៖ «ថ្ងៃនេះពួកយើងមានសំណាងណាស់ដែលមានការពន្យល់ និងបង្រៀនអំពីសិល្បៈរៀបផ្កាអ៊ីកេបាណាដោយលោកគ្រូ ស៊ីនជី ស៊ូកាវ៉ាគី (Shinji Tsukawaki) ដែលជាគ្រូបង្រៀនជាន់ខ្ពស់មកពីសាលាសូហ្គេតស៊ូ (Sogetsu)។ លោកនឹងពន្យល់ពីខ្លឹមសានៃសិល្បៈអ៊ីកេបាណា និងគន្លឹះនៃការរៀបចំរំលេចសម្រស់រុក្ខជាតិទាំងនោះ»។

លោកគ្រូ ស៊ីនជី ស៊ូកាវ៉ាគី បានពន្យល់ពីប្រវត្តិរបស់អ៊ីកេបាណា ដែលត្រូវបានគេស្គាល់តាំងពីជំនាន់មូរ៉ូម៉ាឈី (Muromachi) ពីសតវត្សរ៍ទី១៤រហូតដល់ទី១៦ថាជាសិល្បៈប្រពៃណីជប៉ុន។ សិល្បៈរៀបចំផ្កា និងរុក្ខជាតិអ៊ីកេបាណាស័ក្តិសមទៅនឹងម៉ូដផ្ទះ ឬអគារតាមស្ថាបត្យកម្មបែបជប៉ុន។ សិល្បៈនេះក៏ត្រូវបានគេនិយមប្រើប្រាស់ក្នុងកម្មវិធីទឹកតែ និងសួនច្បារ។

ក្រោយមកក្នុងសតវត្សរ៍ទី១៩ ប្រជាជនចាប់ផ្តើមដាំដុះរុក្ខជាតិបែបបស្ចិមប្រទេសហើយយកផ្កាទាំងនោះមករៀបចំតាមបែបអ៊ីកេបាណា។ ភាពខុសគ្នារវាងការរៀបចំផ្កាតាមបែបអ៊ីកេបាណា និងការរៀបចំតាមបែបបស្ចិមប្រទេសមានលក្ខណៈខុសគ្នា។ ការរៀបផ្កាបែបអ៊ីកេបាណា តម្រូវឲ្យមានមែករុក្ខជាតិ និងតម្រៀបឲ្យមានគម្លាតពីគ្នា ដោយផ្តោតលើទិសដៅតែមួយ។ ចំណែកឯបែបស្ចិមប្រទេសវិញគឺការតុបតែងរៀបចំផ្កា និងរុក្ខជាតិឲ្យពេញថូ និងសាយភាយគ្រប់ទិសដៅតែម្តង៕

0 Comments Please, login or register to post a comment

Latest Video



### បដិមា ៣ អង្គមកដល់កម្ពុជាវិញហើយ

បដិមា ៣ អង្គដែលបានកសាងឡើងក្នុងសម័យកាលព្រះបាទ ជ័យវរ្ម័នទី ៤ ហើយដែលត្រូវបានជនខិលខូចលក់ទៅឲ្យជនបរទេស ត្រូវបានបញ្ជូនមកដល់ប្រទេសកម្ពុជាវិញហើយកាលពីថ្ងៃម្សិលមិញ។



### លោក ហោ ណាំហុង- គំរោងទទួលជនភៀសខ្លួនគឺកំពុងសិក្សា

លោកហោ ណាំហុង រដ្ឋមន្ត្រីក្រសួងបរទេសកម្ពុជា បានលើកឡើងថា រដ្ឋាភិបាលកម្ពុជាមើលឃើញការបញ្ជូនជនភៀសខ្លួនតាមសំណើររបស់រដ្ឋាភិបាលអូស្ត្រាលីសំខាន់លើការស្ម័គ្រចិត្តដោយផ្ទាល់ពីសំនាក់ជនភៀសខ្លួនហើយការសិក

Post Media Co Ltd
888 Building F, 8th Floor, Phnom Penh Center
Corner Sothearos & Sihanoulk Blvd
Sangkat Tonle Bassac
12301 Phnom Penh
Cambodia

Tel: +855(0) 23 214 3 11-17
Fax: +855(0) 23 214 318

Company

Staff list

Sections

ព័ត៌មានជាតិ

Twitter Google +
Facebook

SEVENDAYS

LIFT THE ESSENTIAL MAGAZINE FOR CAMBODIAN YOUTH. >

Copyright © 2013 The Phnom Penh Post. All Rights Reserved. Web design by IConsulting